# ២—សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៦

## សេចក្ដីសំរេចលេខ ០៣ សសរ

## ស្ដីពីការបង្កើតក្រុមដឹកនាំការងារជាតិសំរាប់ឧត្ដមសិក្សា

* * *

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្ដម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

**ប្រការ១** : បង្កើតក្រុមការងារជាតិមួយឈ្មោះថា « ក្រុមដឹកនាំការងារជាតិសំរាប់ឧត្ដមសិក្សា » ដើម្បី អភិវឌ្ឍន៍វិស័យឧត្ដមសិក្សា ។

**ប្រការ២** : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្ដមសិក្សា មានសមាសភាពដូចខាងក្រោម :

+ ឯកឧត្ដម **គាត ឈន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ ប្រធាន

+ ឯកឧត្ដម **តុល ឡោះ** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

+ ឯកឧត្ដម **ជា ចាន់តូ** រដ្ឋមន្ត្រី ក្រសួងផែនការ សមាជិក

+ ឯកឧត្តម **តាវ សេងហួរ** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សមាជិក

+ ឯកឧត្តម **ឈា ចាំង** រដ្ឋមន្ត្រី ក្រសួងសុខាភិបាល សមាជិក

+ ឯកឧត្តម **ពូ សុធីរៈ** រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក

+ ឯកឧត្តម **នុត ណារ៉ាង** រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

+ លោក **អ៊ុច ថុង** តំណាងគ្រឹះស្ថានឧត្តមសិក្សា សមាជិក

+ លោក **តឹក ឆ៊ុយ** តំណាងនយោជកឯកជនជាតិ ទីប្រឹក្សា

+ លោក **អេម្ហ៊ា ជួ** តំណាងនយោជកឯកជនបរទេស ទីប្រឹក្សា

+ លោក **គ្រីស ម៉ាឡូយ** តំណាងនយោជកចំរុះរដ្ឋ - ឯកជន ទីប្រឹក្សា

**ប្រការ៣** : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានសិទ្ធិបង្កើតក្រុមការងារជាតិ ដែលមានសមាសភាពពីស្ថាប័នឧត្តមសិក្សា អ្នកឯកទេស អង្គការផ្តល់ជំនួយ ដើម្បីអនុវត្តការងារ ។

**ប្រការ៤** : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានភារកិច្ចដូចតទៅ :

–ជំនួយការអោយរាជរដ្ឋាភិបាលលើការអភិវឌ្ឍន៍វិស័យឧត្តមសិក្សាក្នុងផែនការសកម្មភាពជាតិ ដើម្បីអោយការវិនិយោគក្នុងវិស័យនេះមានការរីកចំរើនទាន់សភាព – ការណ៍ និងមានប្រសិទ្ធភាព ។

–ដឹកនាំ ត្រួតពិនិត្យ កែលំអផែនការសកម្មភាពជាតិ ដែលរៀបចំឡើង ដោយក្រុមការងារជាតិ ដើម្បីដាក់ជូនសុំសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

**ប្រការ៥** : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា ត្រូវចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ៦** : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សាមានសិទ្ធិប្រើប្រាស់ត្រាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីសំរួលការងារ ។

**ប្រការ៧** : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានអាណត្តិ ១៨ខែ ។

**ប្រការ៨** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងផែន

ការ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បណ្តាស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ០៤ សសរ**

**ស្តីពីការបង្កើតក្រុមការងារសំរាប់សំរួលការ**

**ដោះស្រាយឧបត្ថម្ភដល់បងប្អូនភ្នាក់ងរលើកនៅក្នុងតំបន់ឱ្យវ៉ាល់**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ស្តីពីការបង្កើតអង្គភាពសសំរាប់សំរួលបញ្ហាកងទ័ពរំសាយ និង សមាហរណកម្មក្នុងសង្គមជាតិនូវអតីតទាហានខ្មែរក្រហម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥
- ផ្អែកតាមភាពចាំបាច់ចំពោះមុខ